# ការសម្ភាសន៍របស់អ្នកមីង ចាប សាមឿន

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ចាប សាមឿន

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ចាប សាមឿន

សង្ខេបៈ អ្នកមីង ចាប សាមឿន គាត់មានអាយុហាសិបពីរឆ្នាំ ហើយគាត់បានកើតនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយគាត់មានបងប្អូនចំនួនប្រាំនាក់តែបានស្លាប់អស់ហើយនៅសល់តែពីរនាក់តែប៉ុណ្ណោះ ។ គាត់បានកើតនៅក្នុងក្រុមគ្រួសារដ៏ល្អ ដែលមានឪពុកជាអាចារ្យ ហើយម្តាយដែលមានភាពតស៊ូដើម្បីកូនចៅ។ ហើយគាត់មានប្តីចំនួនពីរនាក់ ប្តីទីមួយរបស់គាត់បានស្លាប់នៅអាយុសែសិបប្រាំឆ្នាំ ហើយគាត់បានយកប្តីមួយទៀតហើយរស់ជាមួយគ្នារាល់ថ្ងៃ។ បំណងប្រាថ្នារបស់គាត់រាល់ថ្ងៃនេះ សង្ឃឹមថាគាត់នឹងបានជាពីជំងឺទាំងអស់នៅក្នុងខ្លួនរបស់គាត់។ គាត់បាននិយាយថាបើគាត់អត់ហូបអោយតែជាក៏គាត់នៅតែសប្បាយដែរ ព្រោះរាល់ថ្ងៃនេះគាត់ពិបាកចិត្តនឹងជំងឺគាត់ណាស់។ធ្វើឡើងនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០១៨។

កៈ អញ្ចឹង ខ្ញុំបាទឈ្មោះ គង់ ចាន់ណាក់ មកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដែលធ្វើឡើងដោយសាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ នៅសហរដ្ឋអាមេរិច ដោយសារតែសាកលវិទ្យាល័យ មានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគេអាច ស្គាល់ពីប្រវត្តិរបស់ជីដូនជីតានិងឪពុកម្តាយរបស់ពួកគេ។ ហើយការសម្ភាសន៍នេះយើងធ្វើនៅ ថ្ងៃទី២២ ខែ០៤ ឆ្នាំ២០១៨ ហើយយើងធ្វើការសម្ភាសន៍នេះនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ហើយអញ្ចឹង សំរាប់ការសម្ភាសន៍នឹងយើងនឹងថតជាសំលេងហើយនឹងថតរូបភាព អ្នកមីង ដើម្បីផ្ញើរទៅកាន់សាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ នៅសហរដ្ឋអាមេរិចដើម្បីពួកគាត់អាចយកទៅដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង តើអ្នកមីងយល់ព្រមអោយយើង យកសំលេងហើយនឹងរូបភាពរបស់អ្នកមីង ដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យដែរទេ អ្នកមីង?

ខ៖ បាន។

ក៖ អរគុណច្រើនអ្នកមីង។ ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ខ្ញុំឈ្មោះ ចាប សាមឿន។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ មានឈ្មោះយាយ ប្រេក។

ក៖ ហើយអញ្ចឹង តើពេលដែលអ្នកមីងនៅក្មេងៗ គេហៅអ្នកមីងថាម៉េចដែរ អ្នកមីង?

ខ៖ កាលនៅក្មេងៗគេហៅខ្ញុំថា យាយប្រេក។

ក៖ អូ! ហៅយាយប្រេក! ហើយអញ្ចឹងសំរាប់អ្នកមីង
សព្វថ្ងៃនេះតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុហាសិបពីរឆ្នាំហើយ។

ក៖ អាយុហាសិបពីរឆ្នាំហើយ! ហើយអញ្ចឹង
តើអ្នកមីងមាននៅចាំថាអ្នកមីងបានកើតនៅឆ្នាំណាទេ អ្នកមីង?

ខ៖ ខ្ញុំកើតនៅឆ្នាំមមែ ហើយកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំបួន។

ក៖ អ្នកមីងកើតឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំបួន ហើយកើតក្នុងឆ្នាំមមែ។
ហើយអញ្ចឹង តើអ្នកមីងបានកើតនៅក្នុងខេត្តណាដែរអ្នកមីង?

ខ៖ ខ្ញុំបានកើតនៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ក៖ ហ្នឹងហើយអ្នកមីងអរគុណ។ ហើយអញ្ចឹង សំរាប់អ្នកមីង
តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ ដែរអ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំនាក់ តែស្លាប់អស់ហើយ នៅសល់តែពីរនាក់ទេ។

ក៖ បាទ! នៅសល់តែពីរនាក់ទេ។ ហើយអញ្ចឹង
តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារ?

ខ៖ ខ្ញុំជាកូនទីបួន។

ក៖ អូ! អ្នកមីងជាកូនទីបួន។ ហើយអញ្ចឹង តើអ្នកមីងមានបងប្អូនប្រុសប៉ុន្មាននាក់
ហើយបងប្អូនស្រី ប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ខ្ញុំមានបងប្រុសពីរនាក់ បងស្រីម្នាក់ ហើយនឹងប្អូនប្រុសម្នាក់។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះបងប្អូនរបស់អ្នកមីងទាំងប្រាំនាក់ បានទេ អ្នកមីង?

ខ៖ បាន បងគេឈ្មោះចាប សឿន បន្ទាប់មក ចាប អួន ហើយបន្ទាប់មកទៀត ចាប សាម៉ន
ហើយ បន្ទាប់មកទៀតខ្ញុំ ចាប សាមឿន ហើយនឹងប្អូនរបស់ខ្ញុំ ចាប សុភាព។

ក៖ ហើយអញ្ចឹង កាលដែលនៅក្មេងៗ
តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ្នកមីង?

ខ៖ ចូលចិត្តមើលគោ មើលក្របី ធ្វើស្រែចំការជាមួយគ្នា។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង
តើពួកគាត់រស់នៅកន្លែងណាខ្លះដែរ អ្នកមីង?

ខ៖ ពួកគាត់ស្លាបអស់ហើយ នៅសល់តែពីរ
ហើយបងស្រីខ្ញុំគាត់ទៅស៊ីឈ្នួលគេនៅប្រទេសថៃ។

ក៖ អូ! អញ្ចឹងគាត់ស៊ីឈ្នួលគេនៅថៃ។ ហើយអញ្ចឹង
សំរាប់ឪពុករបស់អ្នកមីងមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ចាប សៀប ប៉ុន្តែគាត់ស្លាប់ដែលហើយ។

ក៖ អញ្ចឹង គាត់ស្លាប់ហើយអ្នកមីង។ បើសិនគាត់រស់នៅដល់សព្វថ្ងៃនេះ
តើគាត់មានអាយុប៉ុន្មានហើយអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានស្លាប់ពេលដែលគាត់មានអាយុកៅសិបមួយឆ្នាំ។

ក៖ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់បានស្លាប់នៅពេលណាដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានឆ្នាំនៅក្នុងឆ្នាំពីរពាន់ដប់ប្រាំមួយ។

ក៖ អូ! ឪពុករបស់អ្នកមីងគាត់បានស្លាប់ក្នុងឆ្នាំពីរពាន់ដប់ប្រាំមួយ។

ខ៖ គាត់បានស្លាប់ក្នុងខែប្រាំបួន ហើយនៅថ្ងៃទីប្រាំមួយ។

ក៖ គាត់ស្លាប់នៅខែប្រាំបួន ហើយថ្ងៃទីប្រាំមួយ ឆ្នាំពីរពាន់ដប់ប្រាំមួយ។ ហើយអញ្ចឹង
តើឪពុករបស់អ្នកមីងគាត់បានស្លាប់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់បានស្លាប់នៅក្នុងភូមិនឹង។

ក៖ អូ! អញ្ចឹងឪពុករបស់អ្នកមីងគាត់ស្លាប់នៅក្នុងភូមិនឹងតែម្តង។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីង គាត់កើតនៅក្នុងឆ្នាំខ្មែរ ឆ្នាំអ្វីដែរអ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់កើតឆ្នាំឆ្លូវ។

ក៖ អញ្ចឹងគាត់កើតនៅក្នុងឆ្នាំឆ្លូវ។ ហើយអញ្ចឹង សំរាប់ម្តាយរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ ម៉ឺន ហួន តែគាត់ស្លាប់បាត់ហើយ។

ក៖ ហើយអញ្ចឹង តើម្តាយរបស់អ្នកមីងគាត់ស្លាប់អស់រយៈពេលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់បានស្លាប់ជាងម្ភៃឆ្នាំហើយ គាត់បានកើតក្នុងឆ្នាំកុរ។

ក៖ អូ! ម្តាយរបស់អ្នកមីង គាត់កើតឆ្នាំកុរ ហើយគាត់បានស្លាប់ជាងម្ភៃឆ្នាំហើយ។ ហើយគាត់ តើ ម្តាយរបស់អ្នកមីងគាត់បានស្លាប់ដោយសារអ្វីដែរ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់ដោយសារជម្ងឺ គាត់បានស្លាប់ពេលដែលគាត់មានអាយុហាសិបប្រាំបួនឆ្នាំ។

ក៖ ម្តាយរបស់អ្នកមីងគាត់បានស្លាប់ពេលគាត់មានអាយុហាសិបប្រាំបួនឆ្នាំ! ហើយអញ្ចឹង សំរាប់ឪពុកម្តាយរបស់អ្នកមីង កាលគាត់នៅរស់ តើពួកគាត់ប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមជីវិតដែរអ្នកមីង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំគាត់ធ្វើស្រែធ្វើចំការ។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីង គាត់ជាមនុស្សរបៀបណាដែរអ្នកមីង ដូចជាចរិត?

ខ៖ ឪពុកខ្ញុំគាត់ស្លូតបូត គាត់ធ្វើជាអាចារ្យ ពេលខ្ញុំធំដឹងក្តីឡើងគាត់ធ្វើអាចារ្យ។

ក៖ ហើយអញ្ចឹង សំរាប់ម្តាយរបស់អ្នកមីងគាត់មានចរិតដូចម្តេចដែរ?

ខ៖ ម្តាយរបស់ខ្ញុំគាត់ក៏ស្លូតដែរ ម្តាយរបស់ខ្ញុំគាត់ល្អណាស់។

ក៖ ហើយអញ្ចឹង តើឪពុកម្តាយរបស់អ្នកមីងគាត់ធ្លាប់ប្រាប់អ្នកមីងពីជីវិតគាត់ កាលគាត់នៅក្មេងៗទេ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ប្រាប់ខ្ញុំថា ជីវិតរបស់គាត់កំសត់ណាស់គាត់ដើរស៊ីឈ្នួលគេ។

ក៖ ហើយចុះឪពុករបស់អ្នកមីងគាត់ធ្លាប់ប្រាប់ទេពីជីវិតរបស់គាត់ពេលនៅក្មេង?

ខ៖ ឪពុករបស់ខ្ញុំគាត់មិនដែលប្រាប់ទេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីងខ្លួនឯង
តើអ្នកមីងធ្លាប់មានអនុស្សាវរីយ៍ល្អៗជាមួយឪពុកម្តាយរបស់អ្នកមីងដែរឬទេ អ្នកមីង?

ខ៖ មានជាមួយម្តាយរបស់ខ្ញុំច្រើនជាងជាមួយឪពុករបស់ខ្ញុំ។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចជួយប្រាប់ពីបទពិសោធន៍មួយបានទេ
ដូចជាអនុស្សាវរីយ៍មួយដែលអ្នកមីងចាំមិនភ្លេចជាមួយម្តាយ?

ខ៖ ម្តាយរបស់ខ្ញុំពេលគាត់ឈឺក៏គាត់ទៅធ្វើស្រែមិនដែលត្អូញដែរ គាត់តស៊ូជាមួយកូន
ទាល់តែគាត់ ធ្លាក់ខ្លួនឈឺខ្លាំងបានគាត់ប្រាប់ថាឈឺ
បើគាត់នៅឈឺល្មមៗគាត់មិនដែលប្រាប់យើងអោយដឹងទេ
ម្តាយរបស់ខ្ញុំគាត់ជាម្តាយដ៏ល្អណាស់។

ក៖ ហ្នឹងហើយអរគុណច្រើនអ្នកមីង! ហើយអញ្ចឹង
សំរាប់ក្រុមគ្រួសាររបស់អ្នកមីងបានរស់នៅក្នុង
ខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ តាំងតែពីខ្ញុំដឹងក្តីមករស់នៅភូមិនឹងរហូតតែម្តង កើតមកស្រុកកំណើតនៅនឹងតែម្តង។

ក៖ អញ្ចឹងមានន័យថាអ្នកមីងរស់នៅនឹងតាំងពីតូចតែម្តង។ ហើយអញ្ចឹង
តើអ្នកមីងមានសាច់ញាត្តិដទៃទៀតដែលរស់នៅក្រៅប្រទេសខ្មែរទេអ្នកមីង?

ខ៖ អត់មានផង មិនដែលមានទេ។

ក៖ អត់មានទេអ្នកមីង! ហើយអញ្ចឹងសំរាប់ស្វាមីរបស់អ្នកមីង
តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះតាអ៊ឹម នឹងទើបនឹងយកក្រោយទេ។

ក៖ ទើបនឹងយកក្រោយទេ តាអ៊ឹម! ហើយអញ្ចឹងសំរាប់ស្វាមីរបស់អ្នកមីងមុនគាត់នឹង
តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ឈ្មោះតាឌី តែស្លាប់បាត់ហើយ។

កៈ អូ! ស្លាប់បាត់ហើយ។ ហើយអញ្ចឹង តើឈ្មោះពេញរបស់គាត់ឈ្មោះអ្វីដែរអ្នកមីង?

ខៈ គាត់ឈ្មោះ ស៊ីន ឌី។

កៈ ស៊ីន ឌី! ហើយអញ្ចឹង តើស្វាមីមុនរបស់អ្នកមីង គាត់បានស្លាប់នៅអាយុប៉ុន្មានឆ្នាំដែរអ្នកមីង?

ខៈ គាត់បានស្លាប់នៅអាយុសែសិបប្រាំឆ្នាំ។

កៈ គាត់បានស្លាប់អាយុសែសិបប្រាំឆ្នាំ! ហើយអញ្ចឹង
តើអ្នកមីងនៅចាំឆ្នាំកំណើតគាត់ទេអ្នកមីង?

ខៈ គាត់កើតក្នុងឆ្នាំមមី។

កៈ គាត់កើតឆ្នាំមមី! ហើយអញ្ចឹង សំរាប់ឆ្នាំបារាំងអ្នកមីងអត់ចាំទេ?

ខៈ អត់ចាំទេ។

កៈ ហើយអញ្ចឹង តើគាត់បានស្លាប់នៅអាយុប៉ុន្មានឆ្នាំដែរ អ្នកមីង?

ខៈ គាត់បានស្លាប់នៅអាយុសែសិបប្រាំឆ្នាំ។

កៈ គាត់ស្លាប់អាយុសែសិបប្រាំឆ្នាំ! ហើយអញ្ចឹង
សំរាប់ប្តីមុនរបស់អ្នកមីងតើគាត់បានស្លាប់អស់ រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ គាត់ស្លាប់យូរហើយ មិនសូវបានរីវរល់ខ្វល់ខ្វាយជាមួយគាត់ផង
បើយើងបានយកប្តីមួយទៀតហើយនឹង។

កៈ ហើយអញ្ចឹង សំរាប់ស្វាមីក្រោយរបស់អ្នកមីង
តើសព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ ស្វាមីក្រោយរបស់ខ្ញុំគាត់មានអាយុហុកសិបប្រាំមួយឆ្នាំហើយ។

កៈ គាត់អាយុហុកសិបប្រាំមួយឆ្នាំ! ហើយអញ្ចឹង អ្នកមីងមាននៅចាំឆ្នាំកំណើតគាត់ទេ?

ខៈ ឆ្នាំកំណើតគាត់គឺឆ្នាំថោះ។

កៈ អូ! គាត់កើតឆ្នាំថោះ។ ហើយអញ្ចឹង សំរាប់ឆ្នាំបារាំងតើអ្នកមីងមាននៅចាំទេ?

ខៈ ភ្លេចហើយ អត់បានចាំផង។

កៈ ហើយអញ្ចឹង សំរាប់ចំណងអាពាហ៍ពិពាហ៍របស់អ្នកមីងហើយនឹងគាត់នឹង
មានកូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ អត់មានផង។

កៈ អូ! អត់មានសោះតែម្តង។ ហើយអញ្ចឹង សំរាប់អ្នកមីងជាមួយនឹងស្វាមីមុន
តើអ្នកមីងមានកូនទេ អ្នកមីង?

ខៈ ជាមួយស្វាមីមុនមានកូនមួយ។

កៈ ហើយអញ្ចឹង តើកូនរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខៈ កូនរបស់ខ្ញុំគាត់ឈ្មោះ ស៊ីន ពន្លក។

កៈ ស៊ីន ពន្លក! ហើយអញ្ចឹងសំរាប់កូនអ្នកមីង
តើសព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ កូនរបស់ខ្ញុំសព្វថ្ងៃនេះគាត់មានអាយុម្ភៃប្រាំពីរឆ្នាំហើយ។

កៈ ហើយអញ្ចឹង តើអ្នកមីងចាំថាគាត់បានកើតនៅក្នុងឆ្នាំណាទេ?

ខៈ កូនរបស់ខ្ញុំគាត់កើតក្នុងឆ្នាំមមែដែរ។

កៈ អូ! គាត់បានកើតក្នុងឆ្នាំមមែ។ ហើយអញ្ចឹង កូនរបស់អ្នកមីងកើតក្នុងឆ្នាំបារាំង
តើអ្នកមីងមាននៅចាំទេ?

ខៈ អត់ចាំទេ ចាំតែថាគាត់កើតក្នុងឆ្នាំមមែ។

កៈ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានអនុស្សាវរីយ៍អីល្អៗជាមួយកូនទេអ្នកមីង?

ខៈ ធ្លាប់ ធ្លាប់កំសត់ដើរស៊ីឈ្នួលគេដើម្បីចិញ្ចឹមកូន។

កៈ ហ្នឹងហើយ! ស៊ីឈ្នួលគេដើម្បីចិញ្ចឹមកូន តស៊ូដើម្បីកូន។
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍អ្នកមីងហើយនឹងស្វាមីរបស់អ្នកមីងត្រូវបានរៀបចំឡើង
ដោយឪពុកម្តាយរបស់អ្នកមីង ឬមួយរៀបចំឡើងដោយខ្លួនឯង អ្នកមីង?

ខៈ ស្រឡាញ់គ្នាដោយខ្លួនឯង តែឪពុកម្តាយគាត់ជាអ្នករៀបចំអោយ។

កៈ ស្រឡាញ់គ្នាដោយខ្លួនឯង តែឪពុកម្តាយគាត់ជាអ្នករៀបចំអោយយើងមានប្តីប្រពន្ធ។
ហើយ អញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹង មានដូចជាថ្លៃជំនួនទេអ្នកមីង?

ខ៖ អត់មានទេ យើងគ្រាន់តែសែនតិចតួច។

ក៖ អូ! គ្រាន់តែសែនតិចតួចទេអ្នកមីង! ហើយអញ្ចឹង តើអ្នកមីងអាចជួយប្រាប់ពេលដែលអ្នកមីងបានជួបជាមួយប្ដីរបស់អ្នកមីងជាលើកដំបូងបានទេ?

ខ៖ ភ្លេចហើយយូរហើយ ឥឡូវយកប្ដីក្រោយទៀតហើយ។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងចេះអាន ហើយនឹងសរសេរអក្សរខ្មែរដែរឬទេអ្នកមីង?

ខ៖ មើលអត់ឃើញទេ សូម្បីតែមើលលេខទូរស័ព្ទក៏មើលមិនឃើញដែរ។

ក៖ ហើយអញ្ចឹង តើអ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេអ្នកមីង?

ខ៖ អត់ចេះទេ ចេះតែខ្មែរសុទ្ធតែម្ដង។

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្លាប់បានចូលរៀននៅក្នុងសាលាទេ អ្នកមីង?

ខ៖ ធ្លាប់ចូលរៀនបានត្រឹមថ្នាក់ទីបួន ពេលម្ដាយរបស់យើងក្រពេកទៅ ចេះតែដើរធ្វើការទៅ ស៊ីឈ្នួលគេទៅ អត់បានទៅរៀនតែម្ដងទៅ។

ក៖ ហើយអញ្ចឹង សាលាដែលអ្នកមីងបានរៀននឹង នៅកន្លែងណាដែរអ្នកមីង?

ខ៖ ខ្ញុំរៀននៅសាលាព្រៃកោះ។

ក៖ អ្នកមីងរៀននៅសាលាព្រៃកោះ។ ហើយអញ្ចឹង សំរាប់អ្នកមីងចាំឈ្មោះសាលាដែលអ្នកមីងបានរៀនទេ?

ខ៖ ខ្ញុំរៀននៅសាលាបឋមសិក្សាព្រៃកោះ។

ក៖ អូ! សាលាបឋមសិក្សាព្រៃកោះ! ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានមិត្តភក្ដិជិតស្និតដែលធំធាត់មកជាមួយគ្នាតាំងពីក្មេងមក?

ខ៖ មិត្តភក្ដិបែកខ្ញែកគ្នាមានប្ដីមានកូនមានចៅរៀងខ្លួនអស់ហើយ។

ក៖ ប៉ុន្តែអ្នកមីងមានមិត្តជិតស្និតដែរឬទេ?

ខ៖ មាន។

ក៖ ហើយអញ្ចឹង តើមិត្តភក្ដិរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ មានមិត្តភក្តិច្រើនណាស់។

ក៖ អ្នកមីងជួយរាប់ប្រាប់មួយនាក់ពីរនាក់មក?

ខ៖ ឈ្មោះ បូ សរ។

ក៖ បូ សរ! ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានហើយអ្នកមីង?

ខ៖ សព្វថ្ងៃនេះគាត់មានអាយុហាសិបពីរឆ្នាំដូចគ្នានឹងខ្ញុំដែរ។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះអ្នកមីងដឹងថា គាត់រស់នៅកន្លែងណាដែរទេអ្នកមីង?

ខ៖ គាត់រស់នៅក្នុងភូមិពោនយើងនឹងដែរ។

ក៖ អូ! គាត់រស់នៅក្នុងភូមិពោនយើងដែរ។ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះ ជាមួយមិត្តភក្តិកាលនៅក្មេងៗ?

ខ៖ ចូលចិត្តមើលក្របីទាំងអស់គ្នា ទៅរៀនទាំងអស់គ្នា ហើយមើលក្របីទាំងអស់គ្នា។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានធ្វើស្រែចំការទេអ្នកមីង?

ខ៖ សព្វថ្ងៃនេះមានធ្វើស្រែ។

ក៖ អូ! អ្នកមីងមានធ្វើស្រែ។ ហើយអញ្ចឹង
សំរាប់អ្នកមីងមានធ្វើអ្វីផ្សេងក្រៅពីធ្វើស្រែទេអ្នកមីង?

ខ៖ មាន ដើរស៊ីឈ្នួលគេទៅ ដើរលក់នំតិចតួចទៅ។

ក៖ តាំងពីក្មេងរហូតមកដល់ពេលនេះ
តើអ្នកមីងគិតថាជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរទេអ្នកមីង?

ខ៖ អត់ទេ ជីវិតរបស់ខ្ញុំនៅតែដដែល គ្មានការផ្លាស់ប្តូរអីទេ ពីមុនអត់ឈឺទេ
តែឥឡូវឈឺច្រើន។

ក៖ ផ្លាស់ប្តូរឈឺច្រើន។

ខ៖ ភ្នែកក៏ងងឹត ត្រចៀកក៏ថ្លង់ មើលតែលេខទូរស័ព្ទក៏អត់ឃើញផង។

ក៖ តើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេអ្នកមីង?

ខ៖ ខ្ញុំចូលចិត្តសម្លរម្ជូជាងគេ។

កៈ ហើយអញ្ចឹង សំរាប់ល្បែងប្រជាប្រិយវិញ
តើអ្នកមីងចូលចិត្តលេងល្បែងអ្វីខ្លះដែរអ្នកមីង?

ខៈ ពីមុនកាលនៅក្មេងៗចូលចិត្តដើររាំ តែឥលូវអត់ចូលចិត្តផង ចូលចិត្តស្ដាប់ចំរៀង។

កៈ ហើយអញ្ចឹង សំរាប់បទចំរៀងវិញ តើមានបទចំរៀងណាដែលអ្នកមីងចូលចិត្តស្ដាប់
ហើយរៀនច្រៀងតាមតាំងពីក្មេងមកទេ?

ខៈ ចូលចិត្តចំរៀងយីកេ។

កៈ អូ! អ្នកមីងចូលចិត្តចំរៀងយីកេ។ ហើយអញ្ចឹង
តើមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងដែលចេះលេងឧបករណ៍ភ្លេងដែរឬទេ
អ្នកមីង?

ខៈ អត់មានផង គ្មាននរណាចេះលេងទេ។

កៈ អត់មានទេអ្នកមីង! ហើយអញ្ចឹង សំរាប់ផ្ទះមីងផ្ទាល់ខ្លួន
តើផ្ទះនឹងមានលក្ខណៈយ៉ាងដូចម្ដេចតាំងពីក្មេងមក?

ខៈ ផ្ទះខ្ទម។

កៈ ទាបនៅនឹងដី ឬមួយយ៉ាងម៉េចដែរ អ្នកមីង?

ខៈ ខ្ទមទាបនៅនឹងដី។

កៈ ហើយសំរាប់ផ្ទះមួយនឹងអ្នកមីងធ្វើឡើងដោយខ្លួនឯង
ឬមួយអ្នកមីងជួលគេអោយធ្វើអោយ?

ខៈ ផ្ទះនឹងម្ដាយឪពុកខ្ញុំជាអ្នកធ្វើ។

កៈ អូ! ឪពុកម្ដាយរបស់អ្នកមីងជាអ្នកធ្វើផ្ទះនឹង។ ហើយអញ្ចឹង
តើអ្នកមីងអាចជួយប្រាប់បានទេថា តើផ្ទះនឹងធ្វើឡើងដោយសំភារៈអ្វីខ្លះដែរ អ្នកមីង?

ខៈ សសរឫស្សី ហើយដំបូលប្រក់ស្លឹក ហើយជញ្ជាំងក៏ស្លឹកដែរ។

កៈ ហើយអញ្ចឹង ផ្ទះមួយនឹង តើនរណាគេជាអ្នកបង្រៀនអោយធ្វើដែរអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ជាអ្នកធ្វើតែម្ដង។

ក៖ អូ! ឪពុករបស់អ្នកមីងគាត់ជាអ្នកធ្វើតែម្តង។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់ធ្វើដោយខ្លួនឯងឬមួយគាត់ទៅរកគេអោយមកជួយធ្វើដែរ?

ខ៖ គាត់ធ្វើជាមួយប្តីប្រពន្ធគាត់ទៅ ហើយកូនជាអ្នកជួយហុចស្លឹក ជីកបង្គោល។

ក៖ អញ្ចឹងធ្វើដោយខ្លួនឯងជាមួយក្រុមគ្រួសារទាំងអស់។ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានដូចជាជំនាញដែលបន្តវេនពីក្រុមគ្រួសារអ្នកមីង ដូចជាវេញវល្លិ៍ផ្តៅ ឬក៏ជំនាញធ្វើស្ករត្នោត អីទេអ្នកមីង?

ខ៖ អត់ទេ អត់ធ្លាប់មានផង។

ក៖ ហើយអញ្ចឹង តើអ្នកមីងអាចប្រាប់បានទេ ពេលដែលលំបាកជាងគេនៅក្នុងជីវិតរបស់អ្នកមីង?

ខ៖ ធ្លាប់ ពេលនៅក្មេងៗធ្លាប់ដើរស៊ីឈ្នួលគេទាំងម៉ែទាំងកូន ទាំងម្តាយខ្ញុំឈឺក៏គាត់ទៅដែរ អត់ដែលមានត្អូញថាម៉ែឈឺទៅមិនរួចទេ ទល់តែគាត់ធ្លាក់ខ្លួនឈឺខ្លាំង ឈឺស្លាប់តែម្តង។

ក៖ ហើយអញ្ចឹង តើអ្នកមីងគិតថាជីវិតយើងរាល់ថ្ងៃនឹង យើងត្រូវធ្វើយ៉ាងម៉េចដើម្បីអោយជីវិតយើងល្អប្រសើរជាង អ្នកមីង?

ខ៖ ខ្ញុំចង់អោយខ្លួនជាទៅបានសប្បាយចិត្ត រាល់ថ្ងៃនឹងពិបាកចិត្តនឹងខ្លួនឈឺតែម្តង បើបានខ្លួនជាដឹងសប្បាយចិត្ត បើអត់ស៊ីក៏សប្បាយចិត្តដែរ។

ក៖ កុំអោយតែមានជម្ងឺ! ហើយអញ្ចឹង រាល់ថ្ងៃនេះអ្នកមីងឈឺអ្វីដែរអ្នកមីង?

ខ៖ រាល់ថ្ងៃមានគីស ហើយចុកភ្លៅផង។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតទេអ្នកមីង ការកូន ការក្មួយ ការបងប្អូនអីចឹងណា?

ខ៖ ធ្លាប់មាន។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានអារម្មណ៍យ៉ាងម៉េចដែរ ពេលដែលមានកម្មវិធីចឹងកើតឡើង?

ខ៖ មានកម្មវិធីចឹងៗកើតឡើងទៅសប្បាយទៅ ពេលមកដល់ផ្ទះវិញទៅឈឺទៅកើតទុក្ខទៀតទៅ។

កៈ ហើយអញ្ចឹង
តើជីវិតរបស់អ្នកមីងមានបានឆ្លងកាត់សម័យសង្គ្រាមពលពតអីទេអ្នកមីង?
ខៈ ធ្លាប់ ប៉ុន្តែបានមើលតែក្របី ពេលនឹងស៊ីបាយរួម
មិនទាន់បានធ្វើស្រែធ្វើចំការទេជំនាន់នឹង ពេលនឹងខ្ញុំនៅក្មេងទេ។

កៈ ហើយអញ្ចឹង ពេលជំនាន់ពលពតនឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំដែរអ្នកមីង?

ខៈ ខ្ញុំមានអាយុដប់មួយឆ្នាំ។

កៈ អ្នកមីងមានអាយុដប់មួយឆ្នាំ។
តើអ្នកមីងអាចជួយរៀបរាប់ជីវិតក្នុងសម័យសង្គ្រាមតិចបានទេ?

ខៈ ខ្ញុំគ្រាន់តែដឹងថាជំនាន់នឹងមើលក្របី ហើយនឹងកាប់ជីតែប៉ុននឹង
អត់ដឹងថាគេប្រើមនុស្សម៉េចៗផងអត់ទាន់។

កៈ តែសំរាប់ជីវិតរបស់អ្នកមីង ផ្ទាល់ខ្លួនឯង នៅក្នុងសម័យនឹង?

ខៈ នៅក្នុងសម័យនឹងដូចថាសប្បាយភ្លើដូចក្មេងអត់ដឹងអីថាគេសំលាប់ម៉េចៗផង
មើលក្របីមួយនឹមគ្នាបីនាក់ ហើយទៅមើលច្រូតជី ច្រូតដើមកន្ទ្រៀងខេត្តច្រូតអីទៅ
ទៅគ្នាច្រើនសប្បាយ តែអត់ដឹងថាគេប្រើមនុស្សម៉េចៗផង។

កៈ អូ! អត់ដឹងថាគេបានសំលាប់មនុស្សម៉េចៗទេ អត់បានដឹងទេមីងណ៎!

ខៈ ឃើញគេជិះឡាន ចង់ទៅជិះឡាននឹងគេដែរ
កាលនោះអត់ដឹងថាគេយកទៅសំលាប់ផង។

កៈ ហើយបើអ្នកមីងចង់ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយ
តើអ្នកមីងចង់ផ្តាំផ្ញើរអ្វីខ្លះដែរអ្នកមីង?

ខៈ ចង់ផ្តាំផ្ញើរអោយកូនចៅជំនាន់ក្រោយអោយគេសប្បាយកុំអោយដូចខ្ញុំ
អោយគេសប្បាយព្រោះប្រទេសកាន់តែជឿនលឿន ខ្ញុំជំនាន់មុនខ្ញុំពិបាក
ហើយមកដល់ឥឡូវពាក់កណ្តាលជីវិតហើយនៅតែពិបានទៀត។

កៈ ហើយអញ្ចឹង បើសិនអ្នកមីងចង់អោយកូនចៅអ្នកមីងជៀសវាង
តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរអ្នកមីង?

ខៈ ចង់អោយពួកគាត់ជៀសវាងពីថ្នាំញៀន ហើយកុំអោយក្រលំបាក។

ក៖ ហើយអញ្ចឹងនៅចុងក្រោយនេះ
ខ្ញុំសូមអរគុណអ្នកមីងសំរាប់ពេលវេលាដែលអ្នកមីងអោយខ្ញុំសម្ភាសន៍អ្នកមីងអំពីខ្សែជីវិតរបស់អ្នកមីង ហើយខ្ញុំសូមជូនពរអ្នកមីងមានសុខភាពល្អ មានកំលាំងមាំមួន នឹងអាចឈ្នះលើឧបសគ្គទាំងឡាយដែលមាននៅក្នុងជីវិតរបស់អ្នកមីង ហើយសូមជូនពរដល់កូនចៅរបស់អ្នកមីងថាពួកគាត់មានសុខភាពល្អ ហើយមានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ដើម្បីប្រកបមុខរបររកស៊ីជាប្រចាំថ្ងៃអោយបានរីកចំរើនជារៀងរាល់ថ្ងៃ ហើយខ្ញុំសង្ឃឹមថា តាមរយៈការសម្ភាសន៍របស់យើងនេះ ថានឹងជួយកូនចៅរបស់អ្នកមីងរៀនអំពីជីវិតជីដូនជីតារបស់ពួកគាត់ដើម្បីពួកគេអាចរៀន ហើយធ្វើតាម ដើម្បីគេអាចយកឈ្នះលើឧបសគ្គទាំងឡាយអ្នកមីង។
អរគុណច្រើនហើយសំរាប់ការសម្ភសន៍។